ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង

អំពើជួញដូរមនុស្ស

លេខ...០៥៥/២២...រ.ប.ក

# របាយការណ៍

# ស្តីពី

# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមករា និងទិសដៅខែកុម្ភៈ ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ បាន៖
  - បន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៊ែលស្សិក ប៉េរូ និងឡាវ ស្តីពី «ការបញ្ជូនទណ្ឌិត»
  - រៀបចំសន្ធិសញ្ញាស្តីពី បត្យាប័ន ជាមួយប្រទេសឥណ្ឌា និងប្រទេសបេឡារូស។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖
  - បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»
  - ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពី «កិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា»។

#### ក.២. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់

- គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន៖
  - ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងជួញដូរមនុស្ស និងអង្គការកាវីតាស្វីស ស្តីពី «ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ឆ្នាំ២០២២-២០២៤»។
  - ប្រជុំសមាជិកគណៈកម្មាធិការ និងមន្ត្រីជំនាញពីតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការ ដៃគូជាតិ និងអន្តរជាតិ ស្តីពី «ការពិនិត្យឡើងវិញនូវ លទ្ធផលការងារ ភាពប្រឈម» (២០១៩-២០២១) និងគំនិតផ្តួចផ្តើមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របន្ត(២០២២-២០២៣) តាមប្រព័ន្ធអនឡាញ។
  - រៀបចំកិច្ចប្រជុំជាច្រើនលើក តាមប្រព័ន្ធអនឡាញ ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកការងារទេសន្តរប្រវេសន៍ នៅទីក្រុងហ្សឺណែវ បណ្តាញអង្គការទេសន្តរប្រវេសន៍របស់អង្គការសហប្រជាជាតិប្រចាំតំបន់ អគ្គលេខាធិការដ្ឋានអាស៊ាន និងជាមួយអន្តរក្រសួង ស្ថាប័ន ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមជាប្រទេសជ័យលាភីក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី ការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៣. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន៖
  - ព្រាងអនុក្រឹត្យ ស្តីពី «របបគោលនយោបាយ សម្រាប់ជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ស្នាក់នៅក្នុងមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍»។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

ខ.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ:

នៅក្នុងខែមករា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៨.៧៤២លើក មានអ្នកចូលរួមសរុប ៣៧៦.១២២នាក់(ស្រី១៨៨.៣១៣នាក់) ដូចមានតារាងលម្អិតខាងក្រោម៖

### តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ<br>ចំនួន ដង/លើក | ផ្សព្វផ្សាយ<br>ចំនួន មនុស្ស | ផ្សព្វផ្សាយ<br>ចំនួន ស្ត្រី | វេទិកាសាធារណៈ<br>ចំនួន ដង/លើក | វេទិកាសាធារណៈ<br>ចំនួន មនុស្ស | វេទិកាសាធារណៈ<br>ចំនួន ស្ត្រី |
|---|---|---|---|---|---|---|---|
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤០ | ១.១៥៣ | ៥៧៣ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៤០ លើក | ១.១៥៣ នាក់ | ៥៧៣ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៥៧១ | ២០.៩១៧ | ១២.៣៣៦ | ៨៥៤ | ៥០.២៤២ | ២៦.៥៧៦ |
| ៣ | ខេត្តបាត់ដំបង | ៨១៦ | ៣៤.១៨៤ | ១៨.០៣៦ | ៥០៦ | ១៣.០៥៤ | ៦.៨៩៥ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៦៥ | ៣៣.៤១០ | ១៧.០៣២ | ១២៣ | ៤.១៨៦ | ១.៨៨៨ |
| ៥ | ខេត្តសៀមរាប | ៧៥ | ៣.៨៩៥ | ២.១១១ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.០១៥ | ២២.៧៣១ | ១២.១២៣ | ៥៩៣ | ១០.៤២៤ | ៥.៣៧៨ |
| ៧ | ខេត្តកំពង់ចាម | ១.៩៤៩ | ១១៤.៥៥៥ | ៦០.៣១៩ | ១.១៩៤ | ៣៥.៥១៩ | ១៦.៣៥៣ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១០ | ២៤៤ | ១៥៩ | ៦ | ២៦៤ | ១៦២ |
| ១០ | ខេត្តស្វាយរៀង | | | | ២៧២ | ៧.៦៨៨ | ៤.១៨៣ |
| ១១ | ខេត្តប៉ៃលិន | ១២២ | ២.៧៦៣ | ៨៩៤ | ៦៥ | ២.៨៧៤ | ៧០០ |
| ១២ | ខេត្តកោះកុង | | | | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ១៦៩ | ៨.៨១៦ | ១៦៤ | ៨៩ | ៣.១៧៥ | ១.៤៨៤ |
| ១៦ | ខេត្តក្រចេះ | ១១ | ៣០១ | ១៦០ | | | |
| ១៧ | ខេត្តកែប | ២៤ | ១.៨៩៧ | ៣៨៤ | ២៥ | ៩១៧ | ៣៦៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៥ | ៨១០ | ២៧៦ | | | |
| ២១ | ខេត្តព្រៃវែង | | | | ១៣ | ២.១០៣ | ៣៣៧ |
| ២២ | ខេត្តត្បូងឃ្មុំ | | | | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៥.២៣២ | ២៤៤.៥២៣ | ១២៣.៩៩៤ | ៣.៤៧០ | ១៣០.៤៤៦ | ៦៤.៣១៩ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>៨.៧៤២ លើក | | ចំនួនមនុស្សសរុប<br>៣៧៦.១២២ នាក់ | | ចំនួនស្ត្រី<br>១៨៨.៣១៣ នាក់ | |

ខ.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន ១១.៥២៤នាក់។
- ខេត្តសៀមរាប៖ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស នៅវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប បានចំនួន២៤លើក (ផ្សាយផ្ទាល់ ១០លើក និងចាក់ផ្សាយឡើងវិញ១៤លើក)។

- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់ និងសកម្មភាពនានាពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ និងការធ្វើអាជីវកម្ម ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩ តាមវិទ្យុ និងទូរទស្សន៍គោកធ្លក សរុបចំនួន **៣.៥៤២**លើក។
- **ខេត្តកំពង់ឆ្នាំង៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនិងការជួញដូរមនុស្ស តាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីឲ្យលោកប្រធានការិយាល័យ ធ្វើការផ្សព្វផ្សាយបន្តទៅដល់នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សាចំពោះមេរៀនដែលពាក់ព័ន្ធ។

ខ.១.៣. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC)

- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស** បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន **១០៣**នាក់(ស្រី៤០នាក់) កុមារ **១៨**នាក់។
- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាក ស្រុកដោយសុវត្ថិភាព ចំនួន **៣.២៨៤**នាក់(ស្រី**១.២៤៩**នាក់) កុមារ **២០១**នាក់(កុមារី**១៧៧**នាក់)។

ខ.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកំពង់ចាម៖**

  -**រដ្ឋបាលក្រុង ស្រុកទាំង១០** ៖បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំគ.ស.ន.ក និងគ.ក.ន.កពាក់ព័ន្ធទៅនឹងការចាប់រំលោភសេពសន្ថៈទៅលើស្ត្រី និង កុមារ និងអំពីបញ្ហាចំណាកស្រុកទៅការងារធ្វើ ចៀសវាងការឆបោកតាមរយៈមេខ្យល់។

  -**មន្ទីរអប់រំ យុវជន និងកីឡាខេត្ត៖** សហការជាមួយក្រុមការងារប្រឆាំងអំពើជួញដូរមនុស្ស ស្រុកជើងព្រៃ ចុះផ្សព្វផ្សាយការបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស ដល់យុវជនទាំង១០ក្រុង ស្រុក ដែលបានមកចូលរួមការបោះជំរំយុវជនថ្នាក់ខេត្ត នៅវិទ្យាល័យ ហ៊ុន សែន ស្គន់ ចំនួន១៥០នាក់។
- **ខេត្តកណ្តាល៖** អនុវត្តតាមផែនការសកម្មភាពបង្ការទប់ស្កាត់ការជួញដូរមនុស្ស របស់គ.ខ.ប.ជ ខេត្ត មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយអំពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈការប្រជុំបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាប្រចាំខែធ្នូ ឆ្នាំ២០២១ និងត្រៀមរៀបចំបើកបវេសកាលឆ្នាំសិក្សាថ្មី នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលមានការចូលរួមពី ថ្នាក់ដឹកនាំមន្ទីរ លោកប្រធានការិយាល័យចំណុះមន្ទីរ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុង/ស្រុកទាំង១១ លោកស្រីនាយិកាវិទ្យាល័យទូទាំងខេត្ត សរុបចំនួន ៦៧នាក់(ស្រី០៣នាក់)។
- **ខេត្តបន្ទាយមានជ័យ៖** បានផ្សព្វផ្សាយអប់រំ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំណាកស្រុកមកពីប្រទេសថៃចំនួន ៣១៨នាក់(ស្រី១២៣នាក់) កុមារ៣១នាក់ និងបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន ០៧នាក់(ស្រី០៥នាក់)។
- **ខេត្តតាកែវ៖** បានបើកវេទិកាថ្នាក់ដឹកនាំ និងកុមារប្រចាំឆ្នាំ២០២១ ក្រោមប្រធានបទ ផ្សព្វផ្សាយ និងការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តិ ឆ្លើយតបនឹងកិច្ចការពារកុមារ ចំនួន ០១លើក មានអ្នកចូលរួមចំនួន ៩៥នាក់(ស្រី៧៥នាក់)។
- **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំធ្វើវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅមណ្ឌលទទួលពលករ កំរៀង ស្ថិតនៅស្រុកកំរៀង។

### ខ.១.៨. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- ខេត្តកំពង់ចាមៈ

-ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានចូលរួមជាវាគ្មិន ក្រោមប្រធានបទ «ការផ្សព្វផ្សាយពីនិតិវិធីដល់ប្រជាពលរដ្ឋចំពោះការរៀបការជាមួយជនបរទេស» ០១លើក។

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន ក្រោមប្រធានបទ បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលា បិទបញ្ចប់គម្រោង ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិរបស់ពលករកម្ពុជា ដែលមានជំនាញទាបនៅប្រទេសថៃ" ដែលអនុវត្តដោយ អង្គការ LSCW និង We World ០១លើក។

- ខេត្តបាត់ដំបងៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរួមចូលជាវាគ្មិននៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅស្រុកកំរៀង និងស្រុកសំពៅលូន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងជាប់ការទាក់ទងសរុបចំនួន ១៦២.៦៧៧នាក់(ស្រី៧៣.៥១៦នាក់) អនីតិជន ១.៧១៦នាក។
    - ចេញដោយស្របចំនួន ១១៦.៣០០នាក់(ស្រី៥២.៧៥៥នាក់) អនីតិជន ៦២៧នាក់។
    - ចេញដោយមិនស្របច្បាប់ចំនួន ៤៦.២៣៧នាក់(ស្រី២០.៧១៧នាក់) អនីតិជន ១.០៨៩នាក់។
    - ជាប់ការទាក់ទងចំនួន ១៤០នាក់(ស្រី៤៤នាក់) អនីតិជន ០១នាក់។
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១២៦.៩៤២នាក់(ស្រី៥៧.៦៣៨នាក់) អនីតិជន ១.៦០៥នាក់(ស្រី៧៧៣នាក់) ។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ(នគរបាល និងយោធា) បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចំនួន ០៧លើក មនុស្ស ១៣៣នាក់ (ស្រី៤៨នាក់) អនីតិជន២៩នាក់ បានធ្វើកិច្ចសន្យាការអប់រំ និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។
- កម្លាំងជំនាញវរៈនគរបាលការពារព្រំដែនគោក ខេត្តបាត់ដំបង បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបាន ០៤លើក បានទប់ស្កាត់ពលករខ្មែរឆ្លងដែនខុសច្បាប់ ៩៧នាក់(ស្រី៤៤នាក់) អនីតិជន២៥នាក់ បានធ្វើកិច្ចសន្យាការអប់រំ និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលមានបំណងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ០២លើក មនុស្ស ០៨នាក់(ស្រី ០៥នាក់) អនីតិជន០១នាក់ បានធ្វើកិច្ចសន្យាការអប់រំ និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងបញ្ជូនមេខ្យល់ ០១នាក់ ទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

### ខ.២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត ព្រៃវែង ក្រចេះ កំពត និងខេត្តបន្ទាយមានជ័យ បានចុះល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើសអាជីវកម្មផ្លូវភេទ ចំនួន១០លើក។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ និងខេត្តតាកែវ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៥១គោលដៅ មនុស្សចំនួន ២០៤នាក់(ស្រី១៤១នាក់)។

### ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ចំនួន**១២៧**នាក់ និងបានសាកសួរសុខទុក្ខនារីខ្មែរដែលរៀបការរួចទៅរស់នៅក្រៅប្រទេស(កូរ៉េខាងត្បូង) ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាម៉ីខ្លួនបានចំនួន ១៣នាក់(ស្រី០៣នាក់) រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ០២លើក ជាលទ្ធផលឃើញថា ការថែទាំ និងការឧបត្ថម្ភដល់កុមារ បានដំណើរការល្អប្រសើរ។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រសហាគ្រាស កន្លែងលាងឡាន និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០ឆ្នាំដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២០នាក់ (ស្រី ០៤នាក់) ក្នុងនោះជនបរទេស ០៦នាក់ (ជនជាតិចិន ០៥នាក់ និងថៃ ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៥៩នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុពី១៨ឆ្នាំឡើង ៤២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៥នាក់ និងប្រគល់ឱ្យគ្រួសារ ៥៤នាក់) ក្នុងនោះមានបែកជា៖

#### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៣នាក់ (ស្រី ០២នាក់) ក្នុងនោះជនបរទេស ០៦នាក់ (ជនជាតិចិន ០៥នាក់ និងថៃ ០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ៤១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ៣៩នាក់ (ប្រគល់ឱ្យគ្រួសារ ៤១នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៤ | ២២ | ០៥ | ថៃ១ |
| -អំពើលក់ដូរមនុស្ស | ០១ | ០៤ | ០៥ | ចិន៥ |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០១ | គ្មាន | ០១ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ១២ | ០១ | |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០៣ | ០១ | |
| *សរុប* | *០៨ករណី* | *៤១ នាក់* | *១៣ នាក់* | *០៦ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៧ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៧នាក់(ស្រី០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៨នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៧នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៥នាក់ និងប្រគល់ឱ្យគ្រួសារ ១៣នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ស្ថានទម្ងន់ទោស នៃសញ្ញារកម្ម | ០១ | ០៥ | ០១ |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០៧ | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៦ | ០៤ |
| *សរុប* | *០៧ នាក់* | *១៨ នាក់* | *០៧ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួង ស.អ.យ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុប ២៥នាក់ (ស្ត្រី១៩នាក់ កុមារី០២នាក់) មកពីប្រទេសចិន១៥នាក់ ម៉ាឡេស៊ី០៤នាក់ វៀតណាម០៤នាក់ និងថៃ០២នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ១៤នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម០៤នាក់ ជួញដូរកម្លាំងពលកម្ម០២នាក់ ងាយរងគ្រោះ០៤នាក់ និងសង្ស័យថាជាមេខ្យល់០១នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាន**នគរបាលខេត្ត ចំនួន ០៦ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម សរុបមនុស្សចំនួន ១៦.៧៥៥នាក់(ស្រី៥.៣៥៣នាក់) អនីតិជន ១.៣៣៧នាក់ ក្នុងនោះមានៈ

- ខេត្តបន្ទាយមានជ័យ មនុស្សចំនួន ១០.៥៤៩នាក់ (ស្រី ៤.២២៣នាក់) អនីតិជន ៦៦៥នាក់។
- ខេត្តបាត់ដំបង មនុស្សចំនួន ១.១៥០នាក់ (ស្រី ៥៧នាក់) អនីតិជន ១៣នាក់។
- ខេត្តកោះកុង មនុស្សចំនួន ៣១៨នាក់ (ស្រី ១១៧នាក់) អនីតិជន ៦៦នាក់។
- ខេត្តឧត្តរមានជ័យ មនុស្សចំនួន ៤.៦៤៨នាក់ (ស្រី ៩១១នាក់) អនីតិជន៥៩៣នាក់។
- ខេត្តស្វាយរៀង មនុស្សចំនួន ០៤នាក់ (ស្រី ០៤នាក់)។
- ខេត្តតាកែវ មនុស្សចំនួន ៨៦នាក់ (ស្រី ៤១នាក់)។

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ២៥នាក់(ស្រី១៧នាក់) មកពីប្រទេសចិន១៤នាក់(ស្រី) និងម៉ាឡេស៊ី១១នាក់(ស្រី០៣នាក់)។ ជាលទ្ធផល ជនរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធម្មជាតិចំនួន ១០នាក់ ស្នាក់នៅដោយខុសច្បាប់ចំនួន ១៤នាក់(ស្រី០៣នាក់) និងមិនរងគ្រោះ ០១នាក់ ជនរងគ្រោះខាងលើទៅតាមរយៈមេខ្យល់ផ្សេងៗគ្នាមិនស្គាល់អត្តសញ្ញាណ បច្ចុប្បន្នប្រគល់ឱ្យមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា។

**ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប២៣នាក់(ស្ត្រី០១នាក់ កុមារា០៤នាក់ កុមារី១៧នាក់) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម១០នាក់ ជួញដូរកម្លាំងពលកម្ម០២នាក់ ជួញដូរផ្លូវភេទ០២នាក់ និងរំលោភបំពានផ្លូវភេទ១៤នាក់ ក្នុងនោះមានៈ អង្គការក្តីស្រឡាញ់គ្មានព្រំដែន១១នាក់ អង្គការសង្គ្រោះនិងថែទាំអន្តរជាតិស៊ីធីកញ្ញា០៩នាក់ អង្គការរតនៈអ៊ីធីណេសិនណល០១នាក់ អង្គការកឿនៗ០១នាក់ និងអង្គការគ្រួសារថ្មី០១នាក់។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ(រតនៈអ៊ីនធីណេសិនណល មូលនិធិហាការ សង់គ្រាល់) សមាហរណកម្មស្ត្រីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ១៤នាក់ ក្នុងនោះទៅផ្ទះវិញដោយខ្លួនឯងចំនួន០៨នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃដើម្បី កុមារ (APLE) AIM, SWAT និងស្ថានទូតអាមេរិក(FBI) បើកវគ្គបណ្តុះបណ្តាលជំនាញដល់នាយនគរបាល នៃស្នងការនគរបាលរាជធានី-ខេត្ត ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនិងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ការគាំទ្រដល់កុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាកុមារ ក្នុងនីតិវិធីព្រហ្មទណ្ឌ និងសេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចកុមារ។ | ០៤ | ២០៥ | ៤១ |
| **ខេត្តសៀមរាប៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការជីវិតនៃកម្ពុជា និងអង្គការ Unicef បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ | ០២ | ១០៤ | ១៦ |
| **ខេត្តស្វាយរៀង**<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច និងអង្គការ IJM បើកវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីដល់មន្ត្រីសង្គមកិច្ចខេត្ត និងក្រុងស្រុកទាំង៨។ | ០១ | ១៩ | ០៦ |

| | | | |
|---|---|---|---|
| - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុន៥ បើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០៥ | ១០៥ | ៥៩ |
| **ខេត្តតាកែវ៖** បានសហការជាមួយអង្គការម្លប់ឫស្សី បើកវគ្គបណ្តុះបណ្តាល ស្តីពីបណ្តាញកិច្ចការពារកុមារ ដល់មន្ត្រីផ្តល់សេវាសង្គមកិច្ច និងអ្នកពាក់ព័ន្ធថ្នាក់ឃុំ សង្កាត់ ដល់សមាសភាព គ.ក.ន.ក ស្រុក ក្រុង តាមប្រព័ន្ធ Zoom ធ្វើនៅស្រុកទ្រាំង ស្រុកត្រាំកក់ និងក្រុងដូនកែវ។ | ០៣ | ២០៩ | ១៣៨ |
| **ខេត្តរតនគីរី៖** មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាលដល់ក្រុម GBV ស្រុក ស្តីពីបទដ្ឋានអប្បបរមានស្រាប់ផ្តល់ប្រឹក្សាយោបល់ជាមួយមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅស្រុកលំផាត់ចំនួន ២២នាក់ (ស្រី ១១នាក់) និងស្រុកកូនមុំចំនួន ២៤នាក់ (ស្រី ១៣នាក់)។ | ០២ | ៤៦ | ២៤ |
| **ខេត្តព្រៃវែង៖** មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ដល់សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ។ | ០១ | ១៥ | ១៥ |
| **ខេត្តកំពត៖** ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេត និងការឆ្លើយតបបទល្មើសផ្លូវភេទលើកុមារ។ | ០១ | ១៧ | |
| សរុប | ១៩ វគ្គ | ៧២០ នាក់ | ២៩៩ នាក់ |

### ក.២. សិក្ខាសាលា

- **ខេត្តស្វាយរៀង៖** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការហាកា (HAGAR) បើកសិក្ខាសាលា ស្តីពីសិទ្ធិកុមារ និងច្បាប់នានាពាក់ពន្ធ័នឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស ០១លើក មានសិក្ខាកាម ៥៤នាក់(ស្រី៣៧នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ កិច្ចប្រជុំ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ ៖
    - ដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សា កែសម្រួលខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ របស់គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។
    - បើកកិច្ចប្រជុំពាក់ព័ន្ធការធ្វើបច្ចុប្បន្នភាពលើ គោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។
    - បានបើកកិច្ចប្រជុំពិនិត្យ ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្ត ដោយអង្គការដៃគូ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងទិសដៅបន្ត មានអ្នកចូលរួម ១៨រូប (ស្រី០៨រូប)។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖
    - បើកកិច្ចប្រជុំប្រចាំខែ ស្តីពីវឌ្ឍនភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
    - បានបើកកិច្ចប្រជុំត្រួតពិនិត្យបច្ចុប្បន្នភាព និងការបំពេញសាលាកប័ត្រព័ត៌មាននគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។

### ខ.២. ជំនួបពិភាក្សាការងារ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន អញ្ជើញ៖
  - ទទួលជួបពិភាក្សាការងារជាមួយ លោក **សុខ លាំង** អ្នកស្រាវជ្រាវឯករាជ្យ នៃវិទ្យាស្ថានឯករាជ្យក្រៅប្រទេស (ODI) ដែលមានទីតាំងនៅទីក្រុងឡុងប្រទេសអង់គ្លេស និងជាអ្នកសិក្សាស្រាវជ្រាវឱ្យកម្មវិធី ASEAN-ACT ចូលជួបសម្តែងការគួរសម និងអនុញ្ញាតឱ្យសួរសំណួរស្រាវជ្រាវមួយចំនួន ពាក់ព័ន្ធភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្សរបស់ពលករចំណាកស្រុកកម្ពុជា នៅក្នុងបន្ទប់ការងាររបស់ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
  - ទទួលជួបពិភាក្សាការងារជាមួយលេខាស្ថានទូតអាមេរិក ពាក់ព័ន្ធនឹងករណីពពោះជំនួស។
  - ទទួលជួបសម្តែងការគួរសម ជាមួយតំណាងអង្គការ UNICEF Mr. Benjamin, Wildfire Child Protection Specialist និង លោកស្រី **ចាន់ កញ្ញា** មន្ត្រីអភិវឌ្ឍន៍យុវជននិងវ័យជំទង់ ដើម្បីពិភាក្សាពីការពង្រីកកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចការពារកុមារជាជនរងគ្រោះ ងាយរងគ្រោះ និងការពង្រឹងក្រមសីលធម៌របស់មន្ត្រីនៅមណ្ឌលចត្តាឡីស័ក ក៏ដូចជាមន្ត្រីពាក់ព័ន្ធការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅក្នុងចំណោមពលករទេសន្តរប្រវេសន៍ ផ្តោតសំខាន់ស្ត្រីនិងកុមារ។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៥០លើក មានអ្នកចូលរួមសរុប ២៩៦នាក់(ស្រី១៥២)នាក់ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៥លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៨លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ២៧លើក។ (ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។

- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះ

ចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកុម្ភៈ ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។
២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការជួញដូរសរីរាង្គជួញដូរ ការជួញដូរទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។
៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។
៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។
៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។
៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។
៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។
៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្ដោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្ដល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្ដោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្ដាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្ដាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ............ខែ............ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី............ខែ............ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្ដីរាយការណ៍"

-ឯកឧត្ដម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ៥០លើក ) មនុស្សចំនួន ២៩៦នាក់( ស្រី១៥២នាក់ )

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតី៖<br>- កិច្ចប្រជុំពិនិត្យ និងកែសម្រួលអនុស្សរណៈយោគយល់រវាង គ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ នៅសាលប្រជុំគ.ជ.ប.ជ។<br>- បើកសិក្ខាសាលា ការប្រកាសគម្រោងអនុវត្តរួមគ្នា ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រវាងអង្គការកាវីតាសស្វីស និងអង្គការតំណក់ទឹក ជាមួយគ.ជ.ប.ជ ចំនួន ០២លើក។<br>- កិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំពិនិត្យ និងកែសម្រួលអនុស្សរណៈយោគយល់រវាង គ ជ និងអង្គការវីនរ៉ក់អន្តរជាតិ.ប.ជ.ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- បើកកិច្ចប្រជុំពាក់ព័ន្ធការធ្វើបច្ចុប្បន្នភាព លើគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>- កិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់នឹងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៨ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៣ច្បាប់ លិខិតចូល ១៣ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមករាឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមករា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ |

| | |
|---|---|
| | - រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារតី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមូលដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន៧៦ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បាន៖<br>○ អញ្ជើញចូលរួមធ្វើបទបង្ហាញជូនដល់ កងវិស្វកម្មសំណង់លេខ៤៣២ ស្តីពី ទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច នៅសាលហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុសាសន៍ ខេត្តកំពង់ស្ពឺ។<br>○ ទទួលជួប និងធ្វើកិច្ចសម្ភាសជាមួយលោកស្រី បណ្ឌិត Dr. Deanna Davy ស្តីពី ការរៀបចំយន្តការបញ្ជូនឆ្លងកាត់ព្រំដែន សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្តរប្រវេសន៍ដែលត្រូវបានគេកេងប្រវ័ញ្ចនៅប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែលរៀបចំដោយអ្នកជំនាញនៃកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) តាមប្រព័ន្ធអនឡាញ។<br>○ អញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារការពារជនរងគ្រោះ ស្តីពីការពិនិត្យវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ២០២១ បញ្ហាប្រឈម និងលើកទិសដៅការងារ ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម មុំ ប៊ុនថន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅទីស្តីការក្រសួងស.អ.យ។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**<br>- បានចូលរួមប្រជុំពិនិត្យកែសម្រួលលើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់គ.ជ.ប.ជ ដាក់បញ្ចូលទៅក្នុងរបាយការណ៍ឆ្នាំ២០២១របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។<br>- បានបើកកិច្ចប្រជុំផ្ទៃក្នុងក្រុមជំនួយកិច្ចការយុត្តិធម៌ ដើម្បីពង្រឹងវិន័យផ្ទៃក្នុងឡើងវិញ ដឹកនាំសម្របសម្រួលដោយ ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក។<br>- លោកប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមសិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ ស្តីពី «ការលើកកម្ពស់ និងការការពារសិទ្ធិពលករកម្ពុជាដែលមានជំនាញទាបទៅប្រទេសថៃ» នៅសណ្ឋាគារសាន់វេ ភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បាន៖<br>○ អញ្ជើញចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យ និងសេចក្តីសម្រេច ស្តីពីគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (ហ.ស.គ) នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានហ.ស.គ។** |

| | |
|---|---|
| | ○ អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>○ អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.ផ.អ.នៅសណ្ឋាគារសុខាភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុក បាន៖<br>○ អញ្ជើញចូលរួមបើកសិក្ខាសាលាស្តីពី ការប្រកាសគម្រោងអនុវត្តរួមគ្នា អំពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រវាងអង្គការការីតាសស្វីស និងអង្គការតំណក់ទឹក ជាមួយគ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>○ អញ្ជើញចូលរួមបើកកិច្ចប្រជុំពិនិត្យពិភាក្សា សៀវភៅគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប តាមប្រព័ន្ធ ZOOM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**<br>- បានរៀបចំផែនការបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សម្រាប់បើកវគ្គបណ្តុះបណ្តាល នៅខេត្តកោះកុង។<br>- បានបូកសរុបទិន្នន័យពលករកម្ពុជា ដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេស ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ប្រចាំថ្ងៃទូទាំងរាជធានីខេត្តទាំង២៥ ប្រចាំខែមករា ឆ្នាំ២០២២ បានចំនួន **៦.៨៩១នាក់(ស្រី៣.៣២៨នាក់)។** |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - សហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពេទ្យកាល់ម៉ែត សម្របសម្រួលជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលការពិនិត្យនិងព្យាបាលជំងឺ ០១នាក់ (វះកាត់បេះដូង)។<br>- លោកស្រី **ព្រំ សុខន** ប្រធាននាយកដ្ឋាន និងលោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានជួបសម្ភាសជាមួយទីប្រឹក្សាអង្គការ UNDP តាមប្រព័ន្ធអនឡាញ ស្តីពី Development of a transnational referral mechanism for trafficked persons and exploited migrants in the Greater Mekong Sub region.<br>- ចូលរួមកិច្ចប្រជុំក្រុមការងាររបស់គ.ជ.ប.ជ ០២លើក។<br>- រៀបចំកិច្ចប្រជុំលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ ជាមួយក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារការពារជនរងគ្រោះ អង្គការដៃគូពាក់ព័ន្ធ ចំនួន០២លើក នៅទីស្តីការក្រសួងស.អ.យ។<br>- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសកែសម្រួលចុងក្រោយលើសារាចរណែនាំលេខ០០៩ និងទម្រង់គ្រប់គ្រងករណី ជាមួយអង្គការតេរ:អ៊ុនជីណេសិនណល ០១លើក អ្នកចូលរួម ១៥នាក់(ស្រី១០នាក់)។<br>- ប្រជុំក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ស្តីពីការពិភាក្សាលើការងារសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះផ្សេងទៀត នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួម ០៨នាក់(ស្រី០៧នាក់)។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៧លើក អ្នកចូលរួមសរុបចំនួន ២៧២នាក់(ស្រី១៣៥នាក់) | |
|---|---|
| ខេត្តកណ្តាល | - លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ<br>○ បានបើកកិច្ចប្រជុំបូកសរុបលទ្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមករា និងលើកទិសដៅបន្ត ឆ្នាំ២០២២ អ្នកចូលរួមចំនួន២៦នាក់(ស្រី១៩នាក់)។<br>○ បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការ ស្តីពីកិច្ចការពារកុមារ នៅខេត្តកំពង់ធំ ក្រោមអធិបតីភាពឯកឧត្តម **ប្រាក់ សំអឿន** អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ ចំនួន០៥លើក អ្នកចូលរួមចំនួន១៣២នាក់(ស្រី៦៧នាក់)។ |
| ខេត្តព្រៃវែង | - ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជខេត្ត បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ឱ្យធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតពីអំពើជួញដូរមនុស្ស និងល្បិចបោកប្រាស់របស់ជនឆ្លៀតឱកាសមួយចំនួន តាមប្រព័ន្ធ Zoom ចំនួន០២លើក។ |
| ខេត្តសៀមរាប | - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមុស្ស បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០២២ ចំនួន០៣លើក អ្នកចូលរួមចំនួន៧១នាក់(ស្រី១៦នាក់)។<br>- ក្រុមការងារលេខាធិការដ្ឋាន ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមសិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ ស្តីពីការលើកកម្ពស់ការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងកងរាជអាវុធហត្ថខេត្ត បានធ្វើការប្រជុំពិភាក្សាលើកការកំណត់នីតិវិធីក្នុងការទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅតាមសហគ្រាសអាជីវកម្មផលិតឥដ្ឋ ចំនួន០១លើក អ្នកចូលរួមចំនួន០៨នាក់(ស្រី០៤នាក់)។ |
| ខេត្តបន្ទាយមានជ័យ | - ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជខេត្ត បានដឹកនាំកិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ និងប្រកាសសមាសភាពគណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។<br>- លោកស្រី និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងបទដ្ឋាននីតិតវិធីប្រតិបត្តិការ ស្តីពីកិច្ចការពារកុមារ។<br>- ស្នងការនគរបាលខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពី សេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅខេត្តសៀមរាប។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពី ការស៊ើបអង្កេត និងការឆ្លើយតបចំពោះបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណែត នៅខេត្តបាត់ដំបង។<br>○ បានចូលរួមប្រជុំស្តីពី ការត្រួតពិនិត្យការងារប្រឆាំងការសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតផលនៃបទល្មើសសម្អាតប្រាក់ ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនាំបទល្មើសជួញដូរមនុស្ស តាមប្រព័ន្ធ ZOOM។ |

| | |
|---|---|
| ខេត្តតាកែវ | - មន្ទីរកិច្ចការនារីខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី នៅខេត្តសៀបរាម។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការវិភាគលើការអនុវត្តគោលនយោបាយ ឆ្លើយតបនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅខេត្តកោះកុង។<br>○ បានចូលរួមសិក្ខាសាលា ស្តីពីសិទ្ធិកុមារនិងច្បាប់កិច្ចការពារកុមារនានាដែលពាក់ព័ន្ធទៅនឹងកិច្ចការពារ និងផែនការអនុវត្តគោលនយោយបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ នៅខេត្តតាកែវ។ |
| ខេត្តកែប | - លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំលេខាធិការដ្ឋាន គ.ខ.ប.ជ ចំនួន០១លើក ដើម្បីណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធរៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| ខេត្តកំពង់ចាម | - លេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមកិច្ចសិក្ខាសាលាបិទបញ្ចប់វគ្គគម្រោងសិទ្ធិការងារ ការលើកកម្ពស់ និងការការពារសិទ្ធិពលករកម្ពុជា ដែលមានជំនាញទាបទៅប្រទេសថៃ នៅរាជធានីភ្នំពេញ។ |
| ខេត្តឧត្តរមានជ័យ | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ អ្នកចូលរួមចំនួន១៥នាក់(ស្រី១០នាក់)។ |
| ខេត្តកំពង់ឆ្នាំង | - លោកជំទាវប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំកិច្ចប្រជុំប្រចាំខែ មករា ឆ្នាំ២០២២ ០១លើក តាមប្រព័ន្ធអនឡាញ។<br>- ស្រុករលាប្អៀរ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់ស្រុក ០១លើក អ្នកចូលរួម២០នាក់(ស្រី១៩នាក់)។ |